- អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
- តំណាងក្រសួងមហាផ្ទៃ ១រូប	សមាជិក
- តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប	សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប	សមាជិក
- តំណាងក្រសួងទេសចរណ៍ ១រូប	សមាជិក
- តំណាងក្រសួងបរិស្ថាន ១រូប	សមាជិក
- តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប	សមាជិក
- តំណាងក្រសួងសុខាភិបាល ១រូប	សមាជិក
- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប	សមាជិក
- តំណាងសាលារាជធានី ខេត្ត ១រូប	សមាជិក
- តំណាងស្ថានីយទូរទស្សន៍បាយ័ន ១រូប	សមាជិក
- តំណាងធនាគារកាណាឌីយ៉ា ១រូប	សមាជិក

សមាសភាពជាក់ស្តែងរបស់គណៈកម្មការនេះ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ២.-

គណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំផែនការបោះជំរំ
- សម្របសម្រួលការអនុវត្តការងារបោះជំរំយុវជនជាសាកល
- ជំរុញការបោះជំរំជាសាកលឲ្យទូលំទូលាយដល់យុវជនគ្រប់មជ្ឈដ្ឋានទាំងក្នុងនិងក្រៅប្រទេស
- ធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជនដើម្បីរកជំនួយឧបត្ថម្ភនិងផ្លាស់ប្តូរព័ត៌មាន បទពិសោធ និងទស្សនៈរីកចម្រើនដែលទាក់ទងនឹងគោលដៅរួមក្នុងការអភិវឌ្ឍការបោះជំរំយុវជនជាសាកល
- កៀរគរនិងប្រមូលផ្តុំការគាំទ្ររបស់សប្បុរជននិងយុវជនចំពោះការបោះជំរំយុវជនជាសាកល
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារនិងលទ្ធផលនៃការបោះជំរំយុវជនជាសាកល
- ទទួលអនុវត្តការកិច្ចផ្សេងៗដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ប្រការ៣.-

អនុប្រធាននិងសមាជិកនៃគណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល ដូចមានចែងក្នុងប្រការ១ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីចាំបាច់ គណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល មានសិទ្ធិអញ្ជើញអ្នកជំនាញពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ។

ប្រការ៤ .-

គណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល មានសិទ្ធិប្រើត្រានិងនិមិត្តសញ្ញារបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដំណើរការការងាររបស់ខ្លួន។

ប្រការ៥ .-

គណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល មានសិទ្ធិបង្កើតអនុគណៈកម្មការនានាតាមការចាំបាច់។

គណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនជាសាកល មានអគ្គនាយកដ្ឋានយុវជនជាលេខាធិការដ្ឋាន។

ប្រការ៦ .-

ថវិកាចំណាយសម្រាប់ដំណើរការបោះជំរំយុវជនជាសាកល បានមកពីការរួមចំណែកថវិកាបដិភាគរបស់រដ្ឋនិងចំណូលដែលបានមកពីសប្បុរសជននានា។

ប្រការ៧ .-

សេចក្តីសម្រេចលេខ៣១ សសរ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនរដូវក្តៅ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៨ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន(ដូចមានចែងក្នុងប្រការ១) ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..

ប្រកាសអន្តរក្រសួង
ស្តីពី
ការបង្កើតរដូវទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៧
របស់អគ្គនាយកដ្ឋានកីឡា នៃក្រសួងអប់រំ យុវជន និង កីឡា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្រហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យ-បុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ១៦២ អយក.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

ប្រការ ១ ៖

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក៦០ (ការទិញ) ជំពូក៦១ (សោរកម្ម) ជំពូក៦៤ (បន្ទុកបុគ្គលិក) ជំពូក៦២ (អត្ថប្រយោជន៍សង្គម) និងជំពូក៦៥ (ឧបត្ថម្ភកធន) នៅអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ ២ ៖

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

ប្រការ ៣ ៖

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៤ ៖

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៧

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

បណ្ឌិត ហង់ ជួន ណារ៉ុន

កន្លែងទទួល ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ
- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អគ្គនាយកដ្ឋានកីឡា

តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន
ថវិកាកម្មវិធីឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានកីឡា

ឯកតាគិតជារៀល

ចំណូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៧	តណាទាន ដែលជ្រើសរើស	តណាទាន រដ្ឋទេយ្យបុរេប្រទាន	តណាទាន ទូទាត់ធម្មតា	តណាទាន១ជុំបន្ទិល រដ្ឋទេយ្យបុរេប្រទាន	ភាគរយ
				១	២	៣	៤ =២-៣	៥ = ៣/៤ជុំ	៦=៣/២
			សរុប	34,156,400,000	30,129,700,000	5,967,726,000	24,161,974,000	1,491,931,500	19.8%
60			ការទិញ	6,790,800,000	5,310,500,000	1,167,816,000	4,142,684,000	291,954,000	22.0%
	6001		សម្ភារៈថ្នត់ថ្នង់ថែទាំ	169,500,000	169,500,000	169,500,000	0	42,375,000	100.0%
		60011	សម្ភារៈថ្នត់ថ្នង់សម្អាតនិងអនាម័យ	31,200,000	31,200,000	31,200,000	0	7,800,000	100.0%
		60012	សម្ភារៈថ្នត់ថ្នង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ	45,000,000	45,000,000	45,000,000	0	11,250,000	100.0%
		60013	សម្ភារៈថ្នត់ថ្នង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងល្ង	20,000,000	20,000,000	20,000,000	0	5,000,000	100.0%
		60014	សម្ភារៈថ្នត់ថ្នង់សម្រាប់ថែទាំសម្ភារៈឧបករណ៍	59,300,000	59,300,000	59,300,000	0	14,825,000	100.0%
		60015	ប្រេងឥន្ធនៈនិងប្រេងរំអិល	14,000,000	14,000,000	14,000,000	0	3,500,000	100.0%
	6002		សម្ភារៈថ្នត់ថ្នង់ផ្នែករដ្ឋបាល	851,000,000	851,000,000	281,890,000	569,110,000	70,472,500	33.1%
		60021	សម្ភារៈការិយាល័យនិងការបោះពុម្ព	797,200,000	797,200,000	248,090,000	549,110,000	62,022,500	31.1%
		60022	សៀវភៅមើលនិងឯកសារ	18,000,000	18,000,000	18,000,000	0	4,500,000	100.0%
		60028	សម្ភារៈថ្នត់ថ្នង់ផ្នែករដ្ឋបាលផ្សេងៗ	35,800,000	35,800,000	15,800,000	20,000,000	3,950,000	44.1%
	6003		ស្បៀងអាហារនិងផលិតផលកសិកម្ម	68,100,000	68,100,000	68,100,000	0	17,025,000	100.0%
		60031	ស្បៀង	68,100,000	68,100,000	68,100,000	0	17,025,000	100.0%
	6004		សំលៀកបំពាក់និងការគុបតែង	405,700,000	405,700,000	64,300,000	341,400,000	16,075,000	15.8%
		60041	ឯកសណ្ឋាន	402,700,000	402,700,000	61,300,000	341,400,000	15,325,000	15.2%
		60043	មេដាយ(គ្រឿងឥស្សរិយយស)	3,000,000	3,000,000	3,000,000	0	750,000	100.0%
	6005		សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ	3,823,200,000	3,777,200,000	545,026,000	3,232,174,000	136,256,500	14.4%
		60051	សម្ភារៈនិងបរិក្ខារបច្ចេកទេស	680,300,000	680,300,000	106,226,000	574,074,000	26,556,500	15.6%
		60052	សង្ហារឹម	113,000,000	113,000,000	30,000,000	83,000,000	7,500,000	26.5%
		60053	សម្ភារៈប្រើប្រាស់	2,959,900,000	2,959,900,000	384,800,000	2,575,100,000	96,200,000	13.0%
		60054	សម្ភារៈនិងឧបករណ៍ដឹកជញ្ជូន	46,000,000	0	0	0	0	#DIV/0!
		60058	សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារផ្សេងៗ	24,000,000	24,000,000	24,000,000	0	6,000,000	100.0%
	6006		ថាមពលនិងទឹក	1,434,300,000	0	0	0	0	#DIV/0!
		60061	អគ្គិសនី	1,079,000,000	0	0	0	0	#DIV/0!
		60062	ទឹក	355,300,000	0	0	0	0	#DIV/0!
	6007		សម្ភារៈបរិក្ខារថែទាំសុខភាព	36,000,000	36,000,000	36,000,000	0	9,000,000	100.0%
		60071	បំពង់ហ្គាសនិងអុកស៊ីសែន	7,000,000	7,000,000	7,000,000	0	1,750,000	100.0%
		60072	សម្ភារៈបរិក្ខារពេទ្យ	21,000,000	21,000,000	21,000,000	0	5,250,000	100.0%
		60078	សម្ភារៈបរិក្ខារថែទាំសុខភាពផ្សេងៗ	8,000,000	8,000,000	8,000,000	0	2,000,000	100.0%
	6098		សម្ភារៈថ្នត់ថ្នង់ផ្សេងៗ	3,000,000	3,000,000	3,000,000	0	750,000	100.0%
61			សេវាកម្ម	6,330,600,000	5,910,600,000	4,170,570,000	1,740,030,000	1,042,642,500	70.6%
	6102		ការជួលមធ្យោបាយដឹកជញ្ជូន	90,000,000	90,000,000	35,300,000	54,700,000	8,825,000	39.2%
	6104		សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស	478,600,000	478,600,000	445,560,000	33,040,000	111,390,000	93.1%
	6105		ការថែទាំនិងជួសជុល	668,300,000	668,300,000	568,300,000	100,000,000	142,075,000	85.0%

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៧	ឥណទាន ដែលជ្រើសរើស	ឥណទាន រដ្ឋទេយ្យបុរេប្រទាន	ឥណទាន ទូទាត់ធម្មតា	ឥណទាន១ជុំបង្វិល រដ្ឋទេយ្យបុរេប្រទាន	ភាគរយ
				១	២	៣	៤ =២-៣	៥ = ៣/៤ជុំ	៦=៣/២
		61051	ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ផ្នេរ និងដែននេសាទ	8,000,000	8,000,000	8,000,000	0	2,000,000	100.0%
		61052	ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ	236,000,000	236,000,000	236,000,000	0	59,000,000	100.0%
		61053	ការថែទាំនិងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ	30,000,000	30,000,000	30,000,000	0	7,500,000	100.0%
		61054	ការថែទាំបណ្តាញផ្សេងៗ	144,000,000	144,000,000	84,000,000	60,000,000	21,000,000	58.3%
		61056	ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន	110,000,000	110,000,000	90,000,000	20,000,000	22,500,000	81.8%
		61057	ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស	105,000,000	105,000,000	85,000,000	20,000,000	21,250,000	81.0%
		61058	ការថែទាំនិងជួសជុលផ្សេងៗ	35,300,000	35,300,000	35,300,000	0	8,825,000	100.0%
	6107		**សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ**	20,000,000	0	0	0	0	#DIV/0!
		61078	សោហ៊ុយផ្សេងៗទៀត	20,000,000	0	0	0	0	#DIV/0!
	6108		**សោហ៊ុយដឹកជញ្ជូន**	8,000,000	8,000,000	8,000,000	0	2,000,000	100.0%
		61081	សម្ភារៈនិងទំនិញ	8,000,000	8,000,000	8,000,000	0	2,000,000	100.0%
	6109		**បុគ្គលិកខាងក្រៅ**	400,000,000	0	0	0	0	#DIV/0!
		61092	ភ្នាក់ងារបរទេសជាប់កិច្ចសន្យា	400,000,000	0	0	0	0	#DIV/0!
	6110		**ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ**	577,700,000	577,700,000	482,200,000	95,500,000	120,550,000	83.5%
		61101	សោហ៊ុយទទួលភ្ញៀវជាតិ	58,000,000	58,000,000	38,000,000	20,000,000	9,500,000	65.5%
		61102	សោហ៊ុយទទួលភ្ញៀវបរទេស	120,000,000	120,000,000	60,200,000	59,800,000	15,050,000	50.2%
		61103	ប្រជុំ សិក្ខាសាលា និងសន្ទិសីទ	344,700,000	344,700,000	344,700,000	0	86,175,000	100.0%
		61104	ចំណាយរៀបចំពិធីបុណ្យ	20,000,000	20,000,000	20,000,000	0	5,000,000	100.0%
		61105	ចំណាយសម្រាប់វត្ថុអនុស្សាវីយ៍ នៅក្នុងនិងក្រៅប្រទេស	29,000,000	29,000,000	13,300,000	15,700,000	3,325,000	45.9%
		61107	ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ	6,000,000	6,000,000	6,000,000	0	1,500,000	100.0%
	6112		**ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស**	2,415,900,000	2,415,900,000	1,856,860,000	559,040,000	464,215,000	76.9%
		61121	សោហ៊ុយដឹកជញ្ជូន	346,900,000	346,900,000	258,630,000	88,270,000	64,657,500	74.6%
		61122	សោហ៊ុយបេសកកម្ម	344,000,000	344,000,000	262,800,000	81,200,000	65,700,000	76.4%
		61123	សោហ៊ុយស្នាក់នៅ	1,725,000,000	1,725,000,000	1,335,430,000	389,570,000	333,857,500	77.4%
	6113		**ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស**	1,640,000,000	1,640,000,000	759,750,000	880,250,000	189,937,500	46.3%
		61131	សោហ៊ុយដឹកជញ្ជូន	480,000,000	480,000,000	182,500,000	297,500,000	45,625,000	38.0%
		61132	សោហ៊ុយបេសកកម្ម	333,000,000	333,000,000	171,300,000	161,700,000	42,825,000	51.4%
		61133	សោហ៊ុយស្នាក់នៅ	811,500,000	811,500,000	402,450,000	409,050,000	100,612,500	49.6%
		61138	ចំណាយទូទាត់សោហ៊ុយក្រៅប្រទេសផ្សេងៗ	15,500,000	15,500,000	3,500,000	12,000,000	875,000	22.6%
	6114		**សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍**	21,900,000	21,900,000	4,400,000	17,500,000	1,100,000	20.1%
		61141	សោហ៊ុយប្រៃសណីយ៍	2,000,000	2,000,000	2,000,000	0	500,000	100.0%
		61142	សោហ៊ុយទូរគមនាគមន៍	19,900,000	19,900,000	2,400,000	17,500,000	600,000	12.1%
	6198		**សោហ៊ុយនិងសេវាកម្មផ្សេងៗ**	10,200,000	10,200,000	10,200,000	0	2,550,000	100.0%
64			**បន្ទុកបុគ្គលិក**	2,005,600,000	89,200,000	19,700,000	69,500,000	4,925,000	22.1%
	6402		**លាភការនិងប្រាក់បំណាច់ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍**	5,200,000	0	0	0	0	#DIV/0!
		64023	ប្រាក់បំណាច់ម៉ោងបន្ថែម	5,200,000	0	0	0	0	#DIV/0!
	6403		**រង្វាន់និងប្រាក់បំណាច់ផ្សេងៗ**	1,958,200,000	89,200,000	19,700,000	69,500,000	4,925,000	22.1%
		64032	ប្រាក់បំណាច់សម្រាប់ប្រឡង-ប្រឡងប្រជែង	1,869,000,000	0	0	0	0	#DIV/0!
		64033	រង្វាន់	2,000,000	2,000,000	2,000,000	0	500,000	100.0%
		64034	ប្រាក់បំណាច់បុគ្គលិកអង្គភាពផ្សេងៗ	35,000,000	35,000,000	5,200,000	29,800,000	1,300,000	14.9%

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៧	ឥណទាន ដែលជ្រើសរើស	ឥណទាន រដ្ឋទេយ្យបុរេប្រទាន	ឥណទាន ទូទាត់ធម្មតា	ឥណទាន១ធ្នាំបង្វិល រដ្ឋទេយ្យបុរេប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤ជុំ	៦=៣/២
		64036	ប្រាក់ឧបត្ថម្ភត្រូនិងសិក្ខាកាម	5,000,000	5,000,000	5,000,000	0	1,250,000	100.0%
		64038	ប្រាក់បំណាច់ផ្សេងៗ	47,200,000	47,200,000	7,500,000	39,700,000	1,875,000	15.9%
	6405		ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ	42,200,000	0	0	0	0	#DIV/0!
		64051	មន្ត្រីមានជំងឺ	42,200,000	0	0	0	0	#DIV/0!
62			អត្ថប្រយោជន៍សង្គម	18,907,800,000	18,723,800,000	564,340,000	18,159,460,000	141,085,000	3.0%
	6202		ជំនួយសង្គមដល់ប្រជាពលរដ្ឋ	3,460,300,000	3,276,300,000	60,500,000	3,215,800,000	15,125,000	1.8%
		62022	ឱសថ	15,000,000	15,000,000	15,000,000	0	3,750,000	100.0%
		62025	អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស	84,000,000	0	0	0	0	#DIV/0!
		62026	អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្រៅប្រទេស	100,000,000	0	0	0	0	#DIV/0!
		62028	ជំនួយសង្គមផ្សេងៗទៀត	3,261,300,000	3,261,300,000	45,500,000	3,215,800,000	11,375,000	1.4%
	6203		ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គមនិងវប្បធម៌	15,447,500,000	15,447,500,000	503,840,000	14,943,660,000	125,960,000	3.3%
		62035	ឧបត្ថម្ភសហគមន៍កីឡានិងវប្បធម៌	13,554,500,000	13,554,500,000	403,540,000	13,150,960,000	100,885,000	3.0%
		62038	ឧបត្ថម្ភដល់អង្គភាពផ្សេងៗទៀត	1,893,000,000	1,893,000,000	100,300,000	1,792,700,000	25,075,000	5.3%
65			ឧបត្ថម្ភកធន	121,600,000	95,600,000	45,300,000	50,300,000	11,325,000	47.4%
	6502		ឧបត្ថម្ភកធនដល់អង្គការសាធារណៈ	41,200,000	41,200,000	41,200,000	0	10,300,000	100.0%
		65023	ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈអប់រំ និងកីឡា	41,200,000	41,200,000	41,200,000	0	10,300,000	100.0%
	6506		វិភាគទានដល់អង្គការអន្តរជាតិនានា	80,400,000	54,400,000	4,100,000	50,300,000	1,025,000	7.5%
		65064	សហព័ន្ធអន្តរជាតិខាងកីឡាផ្សេងៗ	54,400,000	54,400,000	4,100,000	50,300,000	1,025,000	7.5%
		65068	អង្គការអន្តរជាតិផ្សេងៗទៀត	26,000,000	0	0	0	0	#DIV/0!

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ១៧ ខែ ៣ ឆ្នាំ២០១៧
អគ្គនាយកនៃអគ្គនាយកដ្ឋានគេនាគារជាតិ
អគ្គនាយកនៃ
ម៉ឺញ បានសុវណ្ណអាធិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០១៧
ជ.អគ្គនាយកអគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងអប់រំ យុវជន និងកីឡា
គិន-កោសល្ល

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ២៥ ខែមករា ឆ្នាំ២០១៧
អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា
អ៊ីក-សិទ្ធិជាតិ

ថ្ងៃទី ២៥ ខែមករា ឆ្នាំ២០១៧
ដ្ឋេទេយ្យកបុរេប្រទាន

បានឃើញ និង៦កតាព
ថ្ងៃទី ១០ ខែ ៣ ឆ្នាំ២០១៧
ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
បណ្ឌិត អ៊ីន ព៉ន្ធមុនីវ្ឋ

បានឃើញ និង៦កតាព
ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០១៧
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
បណ្ឌិត ហង់ ជួន ណារ៉ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....សហវ.....

ប្រកាស
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅ នៃប្រកបចេញចូលតែមួយនីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៥៥៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមការិយាល័យមួយចំនួន ក្រោមឱវាទនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងនាយកដ្ឋានទីតាំងកម្ម នៃអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៥៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៨២៣ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីស្តង់ដារ នៃសេវាសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រួច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១.-

ប្រកាសនេះ មានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព សង្គតិភាព និងគណនេយ្យភាព នៃការផ្តល់សេវាសាធារណៈ ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន និងអង្គភាព ដែលបម្រើសេវាសាធារណៈ នៅក្នុងទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមគោលការណ៍អភិបាលកិច្ចល្អ និងកម្មវិធីកែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល។

ប្រការ២.-

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅ នៃច្រកចេញចូលតែមួយទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ថា "ច.ច.ម ទីស្តីការក្រសួង"។

ប្រការ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ផ្នែកទាំងអស់ នៃ ច.ច.ម ទីស្តីការក្រសួង និងអង្គភាពដែលមានសមត្ថកិច្ចពាក់ព័ន្ធ។

ជំពូកទី២
មុខងារ តួនាទី និងភារកិច្ច នៃច្រកចេញចូលតែមួយទីស្តីការក្រសួង

ប្រការ៤.-

ច.ច.ម ទីស្តីការក្រសួង មានមុខងារ និងភារកិច្ច ដូចខាងក្រោម÷

- ផ្តល់ព័ត៌មាន ទម្រង់បែបបទ និងសម្របសម្រួលនីតិវិធី នៃការផ្តល់សេវាសាធារណៈ ជូនសាធារណជន
- ទទួលពាក្យសុំ ឬសំណើសុំសេវាសាធារណៈ ពីសាធារណជន
- ពិនិត្យ និងបញ្ជាក់ភាពគ្រប់គ្រាន់ និងត្រឹមត្រូវតាមលក្ខណៈរដ្ឋបាល នៃសំណើសុំនិងសំណុំឯកសារពាក់ព័ន្ធសេវាសាធារណៈ
- បែងចែក និងបញ្ជូនពាក្យសុំ សំណើសុំ និងសំណុំឯកសារពាក់ព័ន្ធទៅកាន់អគ្គនាយកដ្ឋាន ឬអង្គភាពជំនាញ
- ប្រគល់សេចក្តីសម្រេចពាក់ព័ន្ធការផ្តល់សេវាសាធារណៈជាអាទិ៍ លិខិតគតិយុត្ត អាជ្ញាបណ្ណ ជូនសាធារណជន
- ទទួលមតិយោបល់ និងមតិកែលម្អស្ថាបនា ពីអ្នកប្រើប្រាស់សេវាសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍ ស្តីពីការផ្តល់សេវាសាធារណៈ និងរបាយការណ៍ ស្តីពីចំណូលពីការផ្តល់សេវាសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមនីតិវិធីជាធរមាន
- បំពេញភារកិច្ចផ្សេងទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រការ៥.-

សមាសភាព នៃ ច.ច.ម ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ៦.-

មន្ត្រីរាជការ បុគ្គលិក នៃ ច.ច.ម ទីស្តីការក្រសួង មានមុខងារ និងភារកិច្ច ដូចខាងក្រោម÷

- ទទួលខុសត្រូវរាល់សកម្មភាពទៅតាមផ្នែក ដែលខ្លួនទទួលបន្ទុក នៅក្នុង ច.ច.ម ទីស្តីការក្រសួង ឱ្យដំណើរការប្រកបដោយរលូន ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ចាត់ចែង និងសម្របសម្រួលកិច្ចការប្រចាំថ្ងៃ ក្នុងច.ច.ម ទីស្តីការក្រសួង
- ធានាឱ្យបាននូវការគោរពវិន័យការងារ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត ជាធរមាន
- សហការ សម្របសម្រួល រាល់គ្រប់បណ្តឹង មតិកែលម្អ និងសំណូមពរនានារបស់សាធារណជន និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ផ្តល់ព័ត៌មានដោយប្រុងប្រយ័ត្ន និងត្រូវធានាឱ្យសាធារណជនទុកចិត្ត លើការសន្យារបស់ ច.ច.ម ទីស្តីការក្រសួង ព្រមទាំងទុកចិត្តលើភាពត្រឹមត្រូវ និងភាពពេញលេញ នៃព័ត៌មានដែលបានផ្តល់ជូនសាធារណជន
- ក្នុងម៉ោងបំពេញការងារ មន្ត្រីរាជការ បុគ្គលិក ត្រូវមានវត្តមានជាប្រចាំនៅ ច.ច.ម ទីស្តីការក្រសួង
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ទៅតាមផ្នែកដែលខ្លួនទទួលបន្ទុក ជូនថ្នាក់ដឹកនាំមានសមត្ថកិច្ច ដើម្បីគោរពរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងករណីចាំបាច់
- បំពេញការងារផ្សេងទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រការ៧.-

មន្ត្រីរាជការ បុគ្គលិក នៃច.ច.ម ទីស្តីការក្រសួង ត្រូវប្រកាន់ខ្ជាប់នូវចំណុចមួយចំនួន ក្នុងពេលបំពេញការងារដូចខាងក្រោម÷

- ខិតខំប្រឹងប្រែងបញ្ចេញសមត្ថភាពបំពេញការងារ
- អនុវត្តមុខងារដែលបានប្រគល់ឱ្យស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ជាធរមាន
- ខិតខំបង្កើនចំណេះដឹងខាងបច្ចេកទេស និងចំណេះដឹងផ្ទាល់ខ្លួន ឱ្យបានជាប្រចាំ
- សហការប្រកបដោយផ្លែផ្កា និងត្រូវជួយគ្នាទៅវិញទៅមក ក្នុងការអនុវត្តតួនាទីភារកិច្ច
- ត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការ មានអាកប្បកិរិយា ពាក្យសម្តីសមរម្យ និងមានភាពរួសរាយ រាក់ទាក់ចំពោះសាធារណជន
- បំពេញការងារផ្សេងទៀត ដោយអនុលោមតាមសិទ្ធិ និងករណីយកិច្ចរបស់មន្ត្រីរាជការស៊ីវិល។

ប្រការ៨.-

មន្ត្រីរាជការ បុគ្គលិក នៃ ច.ច.ម ទីស្តីការក្រសួង ត្រូវហាមឃាត់ដាច់ខាតនូវសកម្មភាពណាមួយ ដូចខាងក្រោម÷

- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងទៀត
- យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួន ទៅប្រើដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុតគំរាមកំហែង បំពានសិទ្ធិរបស់សាធារណជន
- ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីរាជការ
- ជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬនាយកប្រតិបត្តិគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល

- បោះពុម្ពផ្សាយ ឬធ្វើការផ្សាយព័ត៌មាន ពាក់ព័ន្ធនៅក្នុងមុខងាររបស់ខ្លួន
- ធ្វើការសន្យាណាមួយ ក្រៅពីរង្វង់សមត្ថកិច្ចសម្រេចរបស់ខ្លួន
- បង្កវិវាទ និងការខ្វែងគំនិតគ្នា ជាមួយសាធារណជន
- បទប្បញ្ញត្តិហាមឃាត់ផ្សេងៗទៀត ដែលមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រការ៩.-

ច.ច.ម ទីស្តីការក្រសួង ត្រូវបែងចែកជាពីរផ្នែក រួមមាន÷

- ផ្នែកជួរមុខ÷ ជាមន្ត្រីរបស់នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ផ្នែកជួរក្រោយ÷ជាមន្ត្រីបង្គោលមកពីអគ្គនាយកដ្ឋាន និងអង្គភាពក្នុងបរិវេណ នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រការ១០.-

ផ្នែកជួរមុខ មានមុខងារ និងភារកិច្ច ដូចខាងក្រោម÷

- សម្របសម្រួលការងាររដ្ឋបាលជារួមរបស់ ច.ច.ម ទីស្តីការក្រសួង
- ទទួលឯកសារពីសាធារណជន និងប្រគល់ឯកសារ ជូនដល់សាធារណជន ព្រមទាំងផ្តល់ព័ត៌មានផ្សេងៗ ពាក់ព័ន្ធសេវាសាធារណៈ ជូនសាធារណជន
- កត់ត្រា តាមដាន សំណុំឯកសារចេញ ចូល ទៅតាមនីតិវិធីរដ្ឋបាល ជាធរមាន
- បែងចែកលិខិតចូលទៅតាមវិស័យនីមួយៗ ជូនផ្នែកជួរក្រោយ
- ផ្សព្វផ្សាយលិខិតជូនដំណឹង និងលិខិតបទដ្ឋានគតិយុត្តជូនសាធារណជន
- សម្របសម្រួលជាមួយ ផ្នែកជួរក្រោយ ដើម្បីបំភ្លឺបញ្ជាក់បន្ថែម ពាក់ព័ន្ធរាល់ព័ត៌មាន និងចម្ងល់ផ្សេងៗជូនសាធារណជន
- បំពេញភារកិច្ចផ្សេងទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំមានសមត្ថកិច្ចពាក់ព័ន្ធ។

ប្រការ១១.-

ផ្នែកជួរក្រោយ នៃ ច.ច.ម ទីស្តីការក្រសួង មានមុខងារ និងភារកិច្ច ដូចខាងក្រោម÷

- ពិនិត្យ និងបញ្ជាក់ភាពគ្រប់គ្រាន់ និងត្រឹមត្រូវតាមលក្ខណៈរដ្ឋបាល នៃសំណើសុំនិងសំណុំឯកសារពាក់ព័ន្ធសេវាសាធារណៈ
- លើកយោបល់ និងបញ្ជូនសំណុំឯកសារស្នើសុំសេវាសាធារណៈ ទៅអគ្គនាយកដ្ឋាន ឬអង្គភាពជំនាញរបស់ខ្លួន ដើម្បីមានចំណាត់ការបន្ត តាមនីតិវិធីផ្នែកក្នុងជាធរមាន
- ផ្តល់ព័ត៌មាន និងសម្របសម្រួលការផ្តល់ព័ត៌មាន អំពីវិធាននិងនីតិវិធី នៃការផ្តល់សេវាសាធារណៈ
- សម្របសម្រួលការបញ្ជូនសេចក្តីសម្រេចពាក់ព័ន្ធការផ្តល់សេវាសាធារណៈ ជាអាទិ៍ លិខិតគតិយុត្ត និងអាជ្ញាបណ្ណ ជូន ច.ច.ម ទីស្តីការក្រសួង
- ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុជាក់លាក់នៃការបដិសេធ ក្នុងករណីសំណើរបស់សាធារណជន ត្រូវបដិសេធបន្ទាប់ពីបានពិនិត្យល្អិតល្អន់ហើយ

- ត្រូវបញ្ជូនឯកសារត្រឡប់ទៅផ្នែកជួរមុខ ដើម្បីកត់ត្រាឯកសារចេញ និងជូនសាធារណជនបំពេញបន្ថែម ឬកែតម្រូវឡើងវិញក្នុងករណីឯកសារមិនទាន់មានភាពគ្រប់ជ្រុងជ្រោយ ឬបំពេញឯកសារស្នើសុំខុសទម្រង់ ឬព័ត៌មានមួយចំនួនមិនច្បាស់លាស់ ឬខ្វះឯកសារភ្ជាប់ផ្សេងៗ ឬករណីសង្ស័យផ្សេងៗ
- ត្រូវបញ្ជូនឯកសារទៅអគ្គនាយកដ្ឋាន និងអង្គភាពសាមី ក្នុងករណីឯកសារមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ
- ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការបដិសេធ ជាលាយលក្ខណ៍អក្សរ ជូនទៅសាធារណជនវិញ ក្នុងករណី សំណើណាមួយរបស់សាធារណជន ត្រូវបដិសេធបន្ទាប់ពីការពិនិត្យល្អិតល្អន់រួច
- ត្រូវប្រគល់ឯកសារពាក់ព័ន្ធការពិនិត្យ និងសម្រេច ជូនសាធារណជន តាមរយៈផ្នែកជួរមុខ ឱ្យបានមុនកាលបរិច្ឆេទកំណត់
- បំពេញភារកិច្ចផ្សេងទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំមានសមត្ថកិច្ចពាក់ព័ន្ធ។

ជំពូកទី៣
កិច្ចដំណើរការការងារ

ប្រការ១២.-

ច.ច.ម ទីស្តីការក្រសួង ត្រូវរៀបចំកិច្ចដំណើរការការងាររបស់ខ្លួន ដូចតទៅ÷

- ត្រូវរៀបចំបិទផ្សាយជាសាធារណៈជាអាទិ៍ នូវប្រភេទសេវាសាធារណៈ ដែលផ្តល់ដោយអគ្គនាយកដ្ឋាននិងអង្គភាពស្ថិតក្នុងបរិវេណទីស្តីការក្រសួង, រយៈពេល, កម្រៃសេវាសាធារណៈ ដោយអនុលោមតាមកម្រងសេវាសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- កម្រៃសេវាសាធារណៈ ត្រូវបិទផ្សាយនៅទីតាំងដែលងាយស្រួលមើលឃើញ និងគ្រប់ពេលវេលា
- ទីកន្លែងដាក់តម្កល់កម្រងសេវាសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់សាធារណជន ដោយអនុលោមតាមគោលការណ៍ នៃការផ្តល់សេវាសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រៀបចំកន្លែងទទួលពាក្យមតិកែលម្អ និងបណ្តឹងតវ៉ា ពីសាធារណជន ដែលមកទទួលសេវាសាធារណៈ ដោយអនុលោមតាមគោលការណ៍ នៃការផ្តល់សេវាសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រការ១៣.-

ក្នុងករណីមន្ត្រីរាជការ ឬ បុគ្គលិកណាម្នាក់ ឈប់សម្រាកពីការងារ ថ្នាក់ដឹកនាំអង្គភាពមានសមត្ថកិច្ច ត្រូវចាត់-បញ្ជូនមន្ត្រី បុគ្គលិក ដែលមានសមត្ថភាពទៅតាមផ្នែក មកប្រចាំការជំនួស ដើម្បីធានានិរន្តរភាពការងារ។

ក្នុងករណីមន្ត្រីរាជការ បុគ្គលិក មិនអាចមកបំពេញការងារបាន ដោយមានឧបសគ្គចាំបាច់ មន្ត្រីរាជការ បុគ្គ-លិកនោះ ត្រូវផ្តល់ព័ត៌មាន ជូនអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន ឱ្យបានទាន់ពេលវេលា។

ប្រការ១៤.-

ក្នុងករណី មានសាធារណជនច្រើនជាប់ជាប្រចាំនៅ ច.ច.ម ទីស្តីការក្រសួង ដែលធ្វើឱ្យគ្មានសណ្តាប់ធ្នាប់ ឬធ្វើឱ្យសាធារណជនត្រូវរង់ចាំយូរ, ច.ច.ម ទីស្តីការក្រសួង ត្រូវមានវិធានការជាបន្ទាន់ ដោយចាត់ចែងឱ្យមានការចែកលេខជូនសាធារណជនតាមលំដាប់សាធារណជន ដែលបានមកដល់ ច.ច.ម ហើយការផ្តល់សេវាសាធារណៈ ត្រូវធ្វើតាមលំដាប់លេខរៀង ដែលបានចែកជូន។

ប្រការ១៥.-

ច.ច.ម ទីស្តីការក្រសួង ត្រូវរៀបចំគ្រាសម្រាប់ប្រើប្រាស់ ដែលរួមមាន ÷

- ត្រាសម្រាប់បោះលើលិខិតចូល
- ត្រាសម្រាប់បញ្ជាក់លើលិខិត ឬឯកសារថតចម្លងនានា
- ត្រាផ្សេងៗទៀតតាមការចាំបាច់។

ប្រការ១៦.-

ច.ច.ម ទីស្តីការក្រសួង ត្រូវរៀបចំឱ្យមានសៀវភៅកត់ត្រា ដូចខាងក្រោម÷

- សៀវភៅកត់ត្រាលិខិតចូល
- សៀវភៅកត់ត្រាលិខិតចេញ
- សៀវភៅកត់ត្រាផ្សេងៗទៀត តាមការចាំបាច់។

ប្រការ១៧.-

មន្ត្រីរាជការ បុគ្គលិក នៃ ច.ច.ម ទីស្តីការក្រសួង ត្រូវបំពេញការងារ ៥ (ប្រាំ) ថ្ងៃ ក្នុងមួយសប្តាហ៍ គឺពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ÷

- **ពេលព្រឹក** ÷ ពីម៉ោង ៧:៣០ នាទី ដល់ម៉ោង ១១:៣០ នាទី
- **ពេលរសៀល÷** ពីម៉ោង ១៤:០០ នាទី ដល់ ម៉ោង ១៧:៣០ នាទី។

ម៉ោងពេលធ្វើការងារប្រចាំថ្ងៃរបស់មន្ត្រីរាជការ បុគ្គលិក នៃ ច.ច.ម ទីស្តីការក្រសួង អាចត្រូវបានកែសម្រួល ឬ ផ្លាស់ប្តូរ តាមការចាំបាច់ ដោយអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ជំពូកទី៤
អវសានប្បញ្ញត្តិ

ប្រការ១៨.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១៩.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល÷
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ១៩
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១៦៦ ឧស.ក.ឧ-ប្រក-០៤

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ឧសា ឆ្នាំ២០១៧

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ ផលិតស៊ីម៉ង់ត៍ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ របស់ក្រុមហ៊ុន បាត់ដំបង ខនស៍ ស៊ីមេន ខមភេនី លីមីធីត ។

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន បាត់ដំបង ខនស៍ ស៊ីមេន ខមភេនី លីមីធីត (BATTAMBANG CONCH CEMENT COMPANY LIMITED.) តំណាងដោយ លោកស្រី ហុង ស្ងួន បង្កើតរោងចក្រ **ផលិតស៊ីម៉ង់ត៍** ដែលមានទីតាំងស្ថិតនៅ តំបន់ភ្នំដូនម៉ាយ ឃុំស្តៅ ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង។

ឈ្មោះផលិតផល	**លេខកូដបំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
ស៊ីម៉ង់ត៍	២៣៩៤

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្ទាំកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ឆ្លាកឈ្មោះរោងចក្រ ៖ " រោងចក្រផលិតស៊ីម៉ងត៍ បាត់ដំបង ខនស៍ ស៊ីមេន ខមភេនី លីមីធីត "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំងការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកជំទែគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់ហ៊ៀសអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបាត់ដំបង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តបាត់ដំបង
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបាត់ដំបង "ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ១៦៣ ឧស-កឧ-ប្រក-០៤ រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០១៧

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ ផលិតស្បែកជើង ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រុមហ៊ុន សាន់ វែល ស៊ូ

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន សាន់ វែល ស៊ូ (SUN WELL SHOES CO., LTD.) តំណាងដោយ លោកស្រី CHEN, LI-LAN បង្កើតរោងចក្រ **ផលិតស្បែកជើង** ដែលមានទីតាំងស្ថិតនៅ ផ្លូវចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	**លេខកូដបំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
ស្បែកជើង	១៥២០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្ទាំកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ឆ្លាកឈ្មោះរោងចក្រ៖ "រោងចក្រផលិតស្បែកជើង សាន់ រ៉ែល ស៊ូ"

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ជាវិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំងការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកជំនួយគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់ហើសអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤: ប្រកាសលេខ ៦១២ ឧថ.ក.ឧ.ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រ ផលិតស្បែកជើង របស់ក្រុមហ៊ុន សាន់ វែល ស៊ូ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ "ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី